## តើផលត្រឡប់នៃឱសថមួយចំនួនដែលអាចកើតមានចំពោះការឆ្លងរោគរបេង (TB) នោះមានអ្វីខ្លះ?

ផលត្រឡប់នៃថ្នាំគ្រាប់កម្រកើតមានណាស់ តែអាចនឹងរួមមាន:

- ការចង់ក្អួត
- ក្អួត
- ទឹកនោមឡើងក្រម៉ៅ
- ការឡើងក្រហមលើស្បែក
- ស្បែក និង/ឬភ្នែកឡើងលឿង
- អត់ឃ្លានចំណីអាហារ
- ស្ពឹកដៃ និង/ឬប្រអប់ជើង

**បើអ្នកប្រឈមនឹងផលត្រឡប់ណាមួយក្នុងចំណោមផលត្រឡប់អស់ទាំងនេះ ចូរប្រាប់ជាបន្ទាន់ទៅវេជ្ជបណ្ឌិត, គិលានុប្បដ្ឋាក, ឬគ្រូពេទ្យតំហែទាំសុខភាពជំនាញរបស់អ្នកដែលមកពីក្រសួងសុខភាពសាធារណៈ។**

## តើក្រសួងសុខភាពសាធារណៈដើរតួនាទីអ្វីខ្លះ?

ក្រសួងនេះមានកង្វល់អំពីអ្នក និងក្រុមគ្រួសាររបស់អ្នក និងផ្តល់ការព្យាបាលសម្រាប់ការឆ្លងរោគរបេង (TB)។ បើអ្នកទទួលបានការព្យាបាលតាមរយៈអង្គភាពសុខភាពសាធារណៈ គ្រូពេទ្យ ឬគិលានុប្បដ្ឋាកដែលបំពេញតួនាទីផ្សព្វផ្សាយបន្ថែម (ERN) អាចនឹងជួបអ្នក។ ក្រុមពេទ្យ ERN គឺជាគិលានុប្បដ្ឋាកដែលទទួលបានការចុះឈ្មោះត្រឹមត្រូវដែលបានទទួលការបណ្តុះបណ្តាលជាពិសេសក្នុងការគ្រប់គ្រងអ្នកជម្ងឺឆ្លងរោគបេង (TB) ឬមានកំពុងមានជម្ងឺរបេង (TB)។ មានតែក្រសួងសុខភាពសាធារណៈនៃខោនធីឡូសអង់ជេឡេសប៉ុណ្ណោះដែលផ្តល់សេវាកម្មនេះ។

| តើវាមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ<br>រវាងការឆ្លងរោគរបេង (TB) និងរោគរបេង (TB) សកម្ម (កំពុងកើតមាន) | |
|---|---|
| **ការឆ្លងរោគរបេង (TB)** | **រោគរបេង (TB) សកម្ម** |
| គ្មានរោគសញ្ញា | ក្អកខ្លាំងរយៈពេលចាប់ពី 3 សប្តាហ៍ឡើងទៅ |
| គ្មានអារម្មណ៍ថាខ្លួនកំពុងមានជម្ងឺ | ក្អកធ្លាក់ឈាម |
| លទ្ធផលធ្វើតេស្តស្បែក ឬឈាមវិជ្ជមាន ឬរកឃើញមាន (តាមធម្មតា) | លទ្ធផលធ្វើតេស្តស្បែក ឬឈាមវិជ្ជមាន ឬរកឃើញមាន (តាមធម្មតា) |
| ការថតកាំរស្មីអ៊ិចលើទ្រូងមានលទ្ធផលដូចប្រក្រតី (តាមធម្មតា) | ការថតកាំរស្មីអ៊ិចលើទ្រូងមានលទ្ធផលមិនប្រក្រតី (តាមធម្មតា) |
| មិនអាចឆ្លងរាលដាលមេរោគរបេង (TB) | មិនសូវឃ្លានអាហារ |
| អាចមានកំណើនមេរោគរបេង (TB) ដែលសកម្ម បើការព្យាបាលមិនចប់ចុងចប់ដើម ឬមិនពេញលេញ។ | ចុះខ្សោយ, ចុករួយ ឬអស់កម្លាំង |
| | គ្រុនរងា, ក្តៅខ្លួន, បែកញើសពេលយប់ |
| | ស្រកទម្ងន់ |

**សម្រាប់ព័ត៌មានបន្ថែមស្តីពីជម្ងឺ/រោគរបេង (TB) ចូរមើលវិបសាយ**
**www.publichealth.lacounty.gov/tb**

Thai CDCP-TB-0002-07 (Rev: 01/21/20)

County of Los Angeles Public Health

# ការឆ្លងរោគរបេង (TB)

## អ្វីៗដែលអ្នកត្រូវដឹងដើម្បីរស់នៅប្រកបដោយសុខភាពល្អ



## តើអ្វីទៅជាការឆ្លងរោគរបេង (TB)?

បើអ្នកមានឆ្លងរោគរបេង (TB) មេរោគ ឬអតិសុខុមប្រាណរបេង (TB) ប្រាកដជាមាន តែ "សម្ងំ" នៅក្នុងខ្លួនអ្នក។ បើអ្នកមានឆ្លងរោគរបេង (TB) អ្នកនឹងមិនមានអាការៈរោគ/រោគសញ្ញា មិនគិតថាខ្លួនឈឺ និងមិនអាចចម្លងមេរោគ ឬអតិសុខុមប្រាណរបេង (TB) ទៅអ្នកមនុស្សផ្សេងៗទៀតបានទេ។ លើសពីនេះ បើប្រព័ន្ធស៊ាំជម្ងឺអ្នកចុះខ្សោយ មេរោគ ឬអតិសុខុមប្រាណរបេង (TB) ទាំងនេះអាចនឹង "ងើបឡើង" ហើយនិងកើនចំនួន។ នៅពេលនោះ អ្នកអាចនឹងធ្លាក់ខ្លួនឈឺដោយសារមានមេរោគរបេង (TB) មានលក្ខណៈសកម្ម។ បើអ្នកកំពុងមានជម្ងឺរបេង (TB) អ្នកមានរោគសញ្ញាដូចជា ក្អកខ្លាំង, បែកញើសយប់, ចុករួយ ឬអស់កម្លាំង, និងស្រកទម្ងន់។ លើសពីនេះទៀត អ្នកអាចចម្លងមេរោគ ឬអតិសុខុមប្រាណរបេង (TB) ទៅអ្នកមនុស្សផ្សេងៗទៀតបាន។ មេរោគរបេង (TB) មានផលប៉ះពាល់ជាសំខាន់ទៅលើសួត តែវាក៏ប៉ះពាល់ដល់ផ្នែកផ្សេងៗទៀតនៃរាងកាយដែរ។ បើបណ្តោយទុកដោយគ្មានការព្យាបាល មេរោគរបេង (TB) អាចនឹងនាំទៅដល់សេចក្តីស្លាប់បាន។

## តើមនុស្សម្នាក់ឆ្លងមេរោគនេះតាមរបៀបណា?



មេរោគ ឬអតិសុខុមប្រាណរបេង (TB) មានជ្រៀតចូលទៅក្នុងខ្យល់ នៅពេលដែលមនុស្សម្នាក់ដែលកំពុងមានជម្ងឺរបេង (TB) នេះក្អក, កណ្តាស, សើច, និយាយ, ឬច្រៀង។ បកអ្នកដកដង្ហើមស្រូបខ្យល់ដែលមានមេរោគ ឬអតិសុខុមប្រាណរបេង (TB) អ្នកអាចនឹងឆ្លងរោគនេះបាន។ យ៉ាងណាមិញ អ្នកមិនអាចឆ្លងរោគរបេង (TB) ពីតាមសម្លៀកបំពាក់, ចាន, ចំណីអាហារ, គ្រែដេក, ឬការប៉ះពាល់ខ្លួនប្រាណផ្ទាល់មនុស្សដែលកំពុងមានជម្ងឺរបេង (TB) បានទេ។

## តើគេព្យាបាលរោគរបេង (TB) យ៉ាងដូចម្តេចខ្លះ?

បើអ្នកមានឆ្លងមេរោគ ឬអតិសុខុមប្រាណរបេង (TB) អ្នកអាចនឹងកើតរោគរបេង (TB) នេះបាន។ បញ្ហានេះអាចកើតមានឡើងភ្លាមៗ ឬជាច្រើនឆ្នាំក្រោយមកទៀត។ គេអាចព្យាបាលរោគរបេង (TB) នេះបានដោយប្រើឱសថដែលជាញឹកញាប់គេប្រើប្រភេទថ្នាំ Isoniazid។ អ្នកត្រូវតែលេបថ្នាំនេះជារៀងរាល់ថ្ងៃសម្រាប់រយៈពេលពីប្រាំមួយទៅប្រាំបួនខែ។ លើសពីនេះ មានរយៈពេលខ្លីជាងមួយ គឺរបបអាហារដែលលាយជាមួយថ្នាំចំនួនពីរប្រភេទដែលគេប្រើប្រចាំសប្តាហ៍សម្រាប់រយៈពេល 12 អាទិត្យ។

## តើហេតុអ្វីទើបបានជាខ្ញុំត្រូវប្រើថ្នាំ បើកខ្ញុំគ្មានអារម្មណ៍ថាធ្លាក់ខ្លួនឈឺនោះ?

អ្នកអាចនឹងមានកំណើនមេរោគរបេង (TB) ដែលសកម្មនៅក្នុងខ្លួន បើអ្នកមិន

ប្រើថ្នាំសម្រាប់ការឆ្លងមេរោគរបេង (TB) ទេនោះ។ មានមេរោគ ឬអតិសុខុមប្រាណរបេង (TB) ជាច្រើនដែលត្រូវបានសម្លាប់ នៅបន្ទាប់ពីអ្នកបានចាប់ផ្តើមការប្រើថ្នាំ តែមួយចំនួនទៀតនៅរស់ក្នុងខ្លួនអ្នករយៈពេលយូរ។ ដរាបណាអ្នកនៅមានមេរោគ ឬអតិសុខុមប្រាណរបេង (TB) នៅក្នុងខ្លួនអ្នក ពួកវាអាច "ងើបឡើង" បង្កើនចំនួន និងធ្វើឲ្យអ្នកធ្លាក់ខ្លួនឈឺបាន។ បើអ្នកកំពុងប្រើ ឬលេបថ្នាំរបេង (TB) វាសំខាន់ណាស់ដែលថា អ្នកត្រូវប្រើថ្នាំនោះឲ្យអស់ នៅពេលដែលវេជ្ជបណ្ឌិត ឬគ្រូពេទ្យតំហែទាំសុខភាពអ្នកចេញវេជ្ជបញ្ជាឲ្យ។

## តើខ្ញុំអាចប្រាប់ដូចម្តេចបាន បើខ្ញុំមានជម្ងឺរបេង (TB)?

ធ្វើតេស្តស្បែក ឬឈាមរកមើលមេរោគរបេង (TB) បើអ្នកបានធ្វើតេស្តស្បែក ចូរធ្វើឲ្យប្រាកដប្រជាថា អ្នកបានត្រឡប់ទៅជួបវេជ្ជបណ្ឌិតអ្នកវិញ ក្រោយរយៈពេលពីរថ្ងៃដើម្បីទទួលបានលទ្ធផលតេស្តរបស់អ្នក។ បើអ្នកបានធ្វើតេស្តឈាម អ្នកមិនចាំបាច់ត្រូវការត្រឡប់ទៅគ្លីនិកដើម្បីទទួលបានលទ្ធផលធ្វើតេស្តរបស់អ្នកទេ។

## តើវានឹងយ៉ាងម៉ិចដែរ បើការធ្វើតេស្តស្បែក ឬឈាមមានលទ្ធផលវិជ្ជមាន (រកឃើញមាន)?

ការធ្វើតេស្តស្បែក ឬឈាមមានលទ្ធផលវិជ្ជមាន (រកឃើញមាន) តាមធម្មតាមានន័យថា អ្នកបានឆ្លងមេរោគ ឬ អតិសុខុមប្រាណរបេង (TB) រួចហើយ តែវាមិនមានន័យសំខាន់ចាំបាច់ដែលថា អ្នកកំពុងធ្លាក់ខ្លួនឈឺ ឬមានមេរោគរបេង (TB) ដែលសកម្មនោះទេ។ ការធ្វើតេស្តផ្សេងៗទៀតដែលមានប្រភេទដូចជា ការថតកាំរស្មីអ៊ិចលើទ្រូង (chest X-ray ឬសំណាកកំហាក (phlegm) មិនចាំបាច់ត្រូវមានដើម្បីពិនិត្យរកមើលឲ្យឃើញនោះទេ បើអ្នកកំពុងធ្លាក់ខ្លួនឈឺ ឬមានមេរោគរបេង (TB) ដែលសកម្ម។

## តើខ្ញុំគប្បីត្រូវធ្វើតេស្តស្បែក ឬឈាមនៅពេលណា?

អ្នកគប្បីទទួលបានការធ្វើតេស្តរកមើលមេរោគរបេង (TB) ក្នុងករណីដែលអ្នក:

- មានរោគសញ្ញាថាកំពុងមានជម្ងឺរបេង
- បានចំណាយពេលនៅជាមួយនឹងមនុស្សម្នាក់ដែលកំពុងមានរោគរបេង (TB)
- មានប្រព័ន្ធស៊ាំជម្ងឺចុះខ្សោយ ដូចជា ហ៊ីវ (HIV) ឬទឹកនោមផ្អែម
- បានចាក់បញ្ចូលថ្នាំញៀនខុសច្បាប់
- បានមក សអរ ថ្មី ដោយចេញពីអាមេរិកឡាទីន, តំបន់សមុទ្រការ៉ាបៀន, ទ្វីបអាហ្វ្រិក, ទ្វីបអាស៊ី, ឬអឺរ៉ុបខាងកើត
- បានធ្វើការ ឬរស់នៅមន្ទីរព្យាបាលរោគ, ជម្រកអ្នកគ្មានផ្ទះសម្បែង, ពន្ធនាគារ, ឬកន្លែងរស់នៅជាក្រុមផ្សេងៗទៀត។